ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែឧសភា ឆ្នាំ២០២១

នៅក្នុងខែឧសភា ឆ្នាំ២០២១នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានផ្ញើសារលិខិតជូនលោកជំទាវប្រធានក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦៥ នៃថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-រុស្ស៊ី

-បានអញ្ជើញថ្វាយបង្គំ និងសួរសុខទុក្ខសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបុទុមវតីរាជវរារាម ដែលកំពុងសម្រាកព្យាបាលព្រះសុខភាព នៅវត្តបុទុមវតីរាជវរារាម រាជធានីភ្នំពេញ

-បានចាត់តាំងឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាជាតំណាង ដើម្បីនាំយកគ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់មួយចំនួនចុះសួរសុខទុក្ខ និងជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋក្រីក្រ ជួបការលំបាកខ្លាំង ក្នុងតំបន់ក្រហមចំនួន១.០០០គ្រួសារ នៅសង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-បានអនុញ្ញាតឱ្យយកទីតាំងក្នុងបរិវេណព្រឹទ្ធសភា ជាទីកន្លែងចាក់វ៉ាក់សាំងដូសទី២ សម្រាប់ចាក់ជូនសម្តេច និងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ, ទីប្រឹក្សាថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារ។

**ក-សកម្មភាពចុះមូលដ្ឋាន**

-នៅក្នុងសភាពការណ៍នៃការប្រយុទ្ធ និងទប់ស្កាត់នៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

១៩ ដោយព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ សម្តេចប្រធានបានអញ្ជើញមកប្រចាំការ ដើម្បីដឹកនាំការងារជំនាញរៀងរាល់ថ្ងៃ និងដឹកនាំចាត់ចែងចូលរួមចំណែកដោះស្រាយជំនួយឧបត្ថម្ភបន្ទាន់រួមមាន៖ អង្ករ ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកផ្លែឈើ ឱសថ និងសម្ភារប្រើប្រាស់មួយចំនួនជូនមន្ត្រី កងកម្លាំង និងប្រជាពលរដ្ឋក្រីក្រដែលរងប៉ះពាល់ពីការបិទខ្ទប់នៅមូលដ្ឋានរាជធានីភ្នំពេញជាបន្តបន្ទាប់។ ព្រមជាមួយនេះ សម្តេចប្រធានក៏បានណែនាំឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ទីប្រឹក្សាថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យជួយដោះស្រាយនូវអំណោយចាំបាច់នានាទៅតាមលទ្ធភាព ដើម្បីចែកជូនប្រជាពលរដ្ឋងាយរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រដែលកំពុងរស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តមួយចំនួនទៀតផងដែរ។

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

**ក-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចុះពិនិត្យការកសាងសមិទ្ធផលនានា និងនាំយកទេយ្យទាន និងគ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារប្រើប្រាស់ និងថវិកាមួយចំនួនប្រគេនដល់ព្រះសង្ឃគង់នៅវត្តទេពនិម្មិត វត្តពង្ររង្សី និងវត្តថ្មទឹកដាច់ ជូនដល់គណៈកម្មការវត្តសម្រាប់តម្កល់ទុកបន្តកសាងវត្ត និងប្រើប្រាស់ ពិសេសសម្ភារចាំបាច់សំខាន់ៗក្នុងការរក្សាការពារទប់ស្កាត់បង្ការការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅស្រុកកំចាយមារ និងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២២ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជូនដល់រដ្ឋបាលស្រុកស្អាង និងស្រុកកោះធំ ខេត្តកណ្តាល សម្រាប់ចែកជូនដល់ប្រជាពលរដ្ឋជួបការលំបាក និងកំពុងធ្វើចត្តាឡីស័ក។

ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារតំណាង

-បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ របស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា

-បានធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយពាក្យបណ្តឹងចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន៦ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធបានចំនួន២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១ករណី

-បានអញ្ជើញចូលរួមប្រជុំពិនិត្យពិភាក្សាអំពីបេក្ខភាពរបស់សភាកម្ពុជាសម្រាប់អាសនៈទំនេរនានារបស់តំបន់អាស៊ី-ប៉ាស៊ីហ្វិក (APG) ក្នុងក្របខ័ណ្ឌសហភាពអន្តរសភា (IPU) ក្រោមអធិបតីភាព ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា និងជាប្រធានគណៈប្រតិភូដឹកនាំកិច្ចប្រជុំសហភាពអន្តរសភា (IPU) នៅសាលប្រជុំពិសេសព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាមួយប្រជុំក្រុមប្រឹក្សាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីស្តាប់របាយការណ៍ស្តីពី វឌ្ឍនភាពការងារខែមេសា និងទិសដៅការងារបន្តឆ្នាំ២០២១ និងបានថ្លែងកោតសរសើរលើកទឹកចិត្តដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបានចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានយ៉ាងម៉ឺងម៉ាត់នូវវិធានការនានា និងបន្តអនុវត្តវិធានការពកាពារ ៣កុំ ជាពិសេសការផ្លាស់ប្តូររបៀបរស់នៅតាមបែបគន្លងថ្មី

-បានអញ្ជើញនាំយកអំណោយគ្រឿងឧបភោគ បរិភោគ ជូនដល់រដ្ឋបាលខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន ដើម្បីចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩

-បានអញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាស្រុកត្បូងឃ្មុំ ដើម្បីស្វែងយល់អំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព នៅខេត្តត្បូងឃ្មុំ

-បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ មេភូមិ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ដើម្បីផ្តល់ការណែនាំអំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងលើកទឹកចិត្តឱ្យឃុំរៀបចំបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន និងគ្រប់ភូមិឱ្យបង្កើតក្រុមដោះស្រាយទំនាស់តាមសំណូមពរនានាក្នុងមូលដ្ឋាន នៅស្រុកគីរីសាគរ និងស្រុកស្រែអំបិល ខេត្តកោះកុង

-បានអញ្ជើញចុះសំណេះសំណាល សួរសុខទុក្ខ នាំយកអំណោយ និងលើកទឹកចិត្តរដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ មន្ត្រី បុគ្គលិក កម្មករ នៃមន្ទីរពេទ្យបង្អែកចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចផ្តល់សេវាលើគ្រប់វិស័យជូនប្រជាពលរដ្ឋ ព្រមទាំងបានណែនាំផ្តាំផ្ញើឱ្យបន្តយកចិត្តទុកដាក់ប្រកបដោយភាពម៉ឺងម៉ាត់ និងទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច សេចក្តីណែនាំ និងវិធានការនានារបស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពជាពិសេសអប់រំណែនាំប្រជាពលរដ្ឋឱ្យផ្លាស់ប្តូរឥរិយាបថរស់នៅ និងប្រកបរបរបែបតាមគន្លងថ្មី អនុវត្តជាប់ជាប្រចាំនូវវិធានការពការពារ និងពាកុំ នៅខេត្តកែប

-បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលការងារស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ ប្រព័ន្ធធារាសាស្ត្រ កសិដ្ឋានដាំបន្លែ និងចិញ្ចឹមសត្វនៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធី សែនជ័យ នៅខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ

-បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ ប្រធានភូមិ អនុភូមិ សមាជិកភូមិ និងប៉ុស្តិ៍រដ្ឋបាលឃុំ ព្រមទាំងបាននាំយកអំណោយប្រគល់ជូនរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សម្រាប់ធ្វើការដោះស្រាយជូនប្រជាពលរដ្ឋកំពុងខ្វះខាតក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវី-១៩ នៅខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តកំពង់ចាម

-បានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយលោកចៅសង្កាត់ ក្រុមប្រឹក្សាសង្កាត់ លោកប្រធានប៉ុស្តិ៍រដ្ឋបាល ដើម្បីស្តាប់របាយការណ៍ស្តីពីការអនុវត្ត

គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ស្ថានភាព និងវិធានការគ្រប់គ្រងជំងឺកូវីដ-១៩ ក្នុងមូលដ្ឋានសង្កាត់ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ន នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

-បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងបានឧបត្ថម្ភនូវគ្រឿងឧបភោគ បរិភោគជូនប្រជាពលរដ្ឋពិការ ចាស់ជរា មានជីវភាពខ្វះខាតចំនួន៥០គ្រួសារ នៅឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

-បានអញ្ជើញជួបសំណេះសំណាល និងស្តាប់របាយការណ៍របស់លោកចៅសង្កាត់ ក្រុមប្រឹក្សាសង្កាត់ លោកប្រធានប៉ុស្តិ៍រដ្ឋបាល អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ស្ថានភាព និងវិធានការគ្រប់គ្រងជំងឺកូវីដ-១៩ ក្នុងមូលដ្ឋាន និងស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋ នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

-ជាអធិបតីក្នុងពិធីចែកអំណោយរ៉ាម៉ាឧនរបស់សមាគមប្រភពល្អកម្ពុជា ជូនដល់ប្រជាពលរដ្ឋដែលកំពុងជួបការលំបាក នៅស្រុកត្បូងឃ្មុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-បាននាំយកអំណោយគ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់មួយចំនួន ប្រគល់ជូនគណៈអភិបាល នៃគណៈអភិបាលស្រុកសន្ទុក ស្រុកបារាយណ៍ និងស្រុកតាំងគោក ខេត្តកំពង់ធំ ដើម្បីទុកផ្គត់ផ្គង់បងប្អូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតក្នុងអំឡុងពេលធ្វើចត្តាឡីស័ក

-បានអញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក ដើម្បីស្តាប់សភាពការណ៍ទូទៅ ជាពិសេសសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្ថានភាពវិវត្តន៍ជំងឺកូវីដ-១៩ និងបាតុភូតធម្មជាតិ នៅស្រុកពញាឮ ខេត្តកណ្តាល

-បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតនៅឃុំគោកគ្រប់ចំនួន៥០គ្រួសារ ឃុំគ្រពាំងវែងចំនួន៥៨គ្រួសារ និងឧបត្ថម្ភថវិកាចំនួន១០,០០០ដុល្លារ ជូនដល់រដ្ឋបាលស្រុកណ្តាលស្ទឹង ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-បានអញ្ជើញចុះជួបសំណេះសំណាល និងលើកទឹកចិត្តក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីនគរបាលប៉ុស្តិ៍សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក ដែលបានខិតខំរួមសហការគ្នាអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល អនុវត្តវិធានការពារការពារ ៣កុំ និងយុទ្ធនាការចាក់វ៉ាក់សាំងស្របតាមផែនការដែលបានកំណត់

-បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកគ្រឿងឧបភោគ បរិភោគចែកជូនក្រុមប្រឹក្សាសង្កាត់បឹងធំ សង្កាត់ប្រទះឡាង សង្កាត់ភ្លើងឆេះរទេះ សង្កាត់ស្នោរ សង្កាត់ឪឡោក ខណ្ឌកំបូល និងសង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្រោយពីការបិទខ្ទប់រាជធានីភ្នំពេញនាពេលកន្លងមក

-ក្នុងបរិបទជំងឺកូវីដ-១៩ ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានបំពេញភារកិច្ចផ្សេងៗទៀត នៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១០៦លើក។

## ២.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាសហភាពអន្តរសភា(IPU) បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួមកិច្ចប្រជុំមហាសន្និបាតលើកទី១៤២ របស់សហភាពអន្តរសភា (IPU) តាមប្រព័ន្ធវីដេអូ

-លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា បានអនុញ្ញាតឱ្យកញ្ញា Sonia Faubert កម្មសិក្សាការីជនជាតិបារាំង-កាណាដា ចូលជួបសម្តែងការគួរសម និងជម្រាបលា។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត **ទេព ងន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*